វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី១២ ខែតុលា ២០១៨**

---

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ការកំណត់ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរនៅកម្ពុជាសំរាប់ឆ្នាំ២០១៩ គឺ ១៨២ដុល្លារ
- មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) កាត់បន្ថយការរំពឹងទុកទៅលើកំណើនសេដ្ឋកិច្ចពិភពលោក ដោយសារតែការរីករាលដាលនៃសង្គ្រាមពាណិជ្ជកម្ម
- ឱនភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកកើនឡើង ដោយសារការនាំចូលកើនឡើង ការនាំចេញធ្លាក់ចុះ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការកំណត់ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរសំរាប់ឆ្នាំ ២០១៩ គឺ ១៨២ដុល្លារ

ការចរចារនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការប្រឹក្សាការងារ រវាងតំណាងរាជរដ្ឋាភិបាល និយោជក និងក្រុមសហជីពកម្មករនៅក្នុងវិស័យកាត់ដេរនិងវាយនភណ្ឌ កាលពីថ្ងៃសុក្រសប្តាហ៍មុនបានប្រព្រឹត្តទៅយ៉ាងរលូន ដោយភាគីពាក់ព័ន្ធបានរួមគ្នាធ្វើសេចក្តីសម្រេចចុងក្រោយស្តីអំពីប្រាក់ឈ្នួលអប្បបរមាសំរាប់ឆ្នាំ២០១៩។ នៅក្នុងឆ្នាំ២០១៩ ប្រាក់ឈ្នួលអប្បបរមានឹងមានចំនួន១៨២ដុល្លារ។

នៅក្នុងដំណាក់កាលចរចារនោះ និយោជកបានសុំអោយតម្លើងប្រាក់ឈ្នួលអប្បបរមាត្រឹមតែ១៧៧ដុល្លារប៉ុណ្ណោះ ខណៈដែលក្រុមសហជីពចំនួន១៦បានស្នើសុំរហូតដល់១៨២ដុល្លារ។ នៅពេលដែលសំណើទាំងនេះត្រូវបានយកទៅបោះឆ្នោតសម្រេចនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ សំណើចំនួន ១៧៧ដុល្លារបានឈ្នះដោយសម្លេងគាំទ្រ។ ទោះបីជាយ៉ាងណាក៏ដោយ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្រេចផ្តល់៥ដុល្លារបន្ថែមទៀតដែលសរុបកើនដល់១៨២ដុល្លារ តាមសំណើរបស់កម្មករ។ ការព្រមព្រៀងនេះពុំមានការផ្លាស់ប្តូរទៅលើប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ផ្សេងទៀតឡើយ។

### តារាងប្រចាំសប្តាហ៍៖ ការចំណាយលើវិស័យអប់រំ និងប្រាក់បៀវត្សរ៍អប្បបរមារបស់មន្ត្រីនៅក្នុងវិស័យអប់រំ

យោងទៅតាមច្បាប់ស្តីពីថវិការជាតិសំរាប់ឆ្នាំ២០១៣ ដល់ឆ្នាំ ២០១៨ និងយោងទៅលើរបាយការណ៍កំណែទម្រង់របស់ក្រសួងមុខងារសារធារណៈឆ្នាំ២០១៨ ថវិកាជាតិដែលបានផ្ទេរអោយវិស័យអប់រំនៅកម្ពុជាមានកំណើនជាមធ្យមក្នុងរង្វង់ប្រហែល២៣%ក្នុងមួយឆ្នាំ។ នៅក្នុងអំឡុងពេលដូចគ្នា ប្រាក់បៀវត្សរ៍អប្បបរមារបស់

មន្ត្រីនៅក្នុងវិស័យអប់រំនៅកម្ពុជាកើនឡើងជាងពីរដង ពី៤០២ ៨០០ រៀលនៅក្នុងឆ្នាំ២០១៣ ដល់១ ១០១ ៨០០រៀល នៅក្នុងឆ្នាំ២០១៨ ដែលមានកំណើនជាមធ្យមប្រមាណ ២៣% ក្នុងមួយឆ្នាំដូចគ្នា។

**ការចំណាយលើវិស័យអប់រំ និងប្រាក់បៀវត្សរ៍អប្បបរមារបស់មន្ត្រីនៅក្នុងវិស័យអប់រំចាប់ពីឆ្នាំ ២០១៣-២០១៨**




ប្រភព៖ ក្រសួងមុខងារសាធារណៈ និងច្បាប់ស្តីពីថវិការជាតិសំរាប់ឆ្នាំ ២០១៣-២០១៨

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) កាត់បន្ថយចក្ខុវិស័យកំណើនសេដ្ឋកិច្ចពិភពលោក ដោយសារតែការរីករាលដាលនៃសង្គ្រាមពាណិជ្ជកម្ម

កាលពីពេលថ្មីៗនេះ IMF បានចេញផ្សាយនូវលទ្ធផលនៃចក្ខុវិស័យសេដ្ឋកិច្ចជាសកលរបស់ខ្លួន ដែលព្យាករណ៍ថាកំណើនសេដ្ឋកិច្ចពិភពលោកអាចនឹងធ្លាក់ចុះសម្រាប់ឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលជាលទ្ធផលនៃសង្គ្រាមពាណិជ្ជកម្ម និងបរិយាកាសគោលនយោបាយដែលមិនមានភាពច្បាស់លាស់។

បរិយាកាសពាណិជ្ជកម្មនេះត្រូវបានគេរំពឹងថាអាចនឹងកាត់បន្ថយការវិនិយោគ បង្កើនភាពទុទិដ្ឋិនិយមទៅលើទីផ្សារ និងបង្កអោយមានភាពប្រែប្រួលមិនទៀងទាត់នៅក្នុងទីផ្សារហិរញ្ញវត្ថុ។

ប្រៀបធៀបទៅនឹងចក្ខុវិស័យរបស់ IMF នៅក្នុងខែកក្កដា កំណើនសេដ្ឋកិច្ចពិភពលោកបានថយចុះពី ៣,៩% មក ៣,៧%សម្រាប់ឆ្នាំ២០១៨។ កំណើនសេដ្ឋកិច្ចរបស់អាមេរិចត្រូវបានគេព្យាករណ៍ប្រមាណជា២,៩%សម្រាប់ឆ្នាំនេះ ប៉ុន្តែនឹងធ្លាក់ចុះត្រឹម ២,១% នៅឆ្នាំក្រោយ។

ចំពោះកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិនត្រូវបានគេព្យាករណ៍ថាមានចំនួន៦,៦%នៅក្នុងឆ្នាំ២០១៨ ប៉ុន្តែនឹងធ្លាក់ចុះត្រឹម៦,២% នៅឆ្នាំបន្ទាប់។

កំណើនសេដ្ឋកិច្ចរបស់សហគមអឺរ៉ុបត្រូវបានគេរំពឹងថា នឹងមានចំនួន២%នៅក្នុងឆ្នាំនេះ ប៉ុន្តែនឹងធ្លាក់ចុះត្រឹម ១,៩%នៅឆ្នាំ២០១៩។

## សេដ្ឋកិច្ចអាមេរិក និងទំនប់ម្រុងសហព័ន្ធ

### ឱនភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកកើនឡើង ខណៈការនាំចូលកើនឡើង និងការនាំចេញថយចុះ

យោងតាមការការចេញផ្សាយចុងក្រោយរបស់ការិយាល័យជំរឿនរបស់អាមេរិច(Census Bureau) បានអោយដឹងថា ឱនភាពពាណិជ្ជកម្មរបស់អាមេរិចបានកើនឡើងពី ៥០ប៊ីលានដុល្លារ នៅក្នុងខែកក្កដា ដល់ ៥៣,២ប៊ីលានដុល្លារក្នុងខែសីហា។ តម្លៃនៃការនាំចូលបានកើនឡើង ០,៦% ស្មើនឹង ២៦២,៧ប៊ីលានដុល្លារ ខណៈតម្លៃនៃការនាំចេញបានធ្លាក់ចុះ ០,៨% ស្មើនឹង ២០៩,៤ប៊ីលានដុល្លារ។

កត្តាដែលជម្រុញអោយការនាំចូលរបស់អាមេរិចកើនឡើង គឺដោយសារតែការនាំចូលរថយន្ត គ្រឿងបន្លាស់ ម៉ាស៊ីន ទូរស័ព្ទ និងសម្ភារៈប្រើប្រាស់ផ្សេងៗមានការកើនឡើង។ រីឯកត្តាដែលជម្រុញអោយការនាំចេញធ្លាក់ចុះ គឺដោយសារតែការនាំចេញសណ្តែកសៀង ប្រេងឆៅ និងផលិតផលប្រេងផ្សេងៗទៀតមានការធ្លាក់ចុះ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះរួមមាន៖ ទិន្នន័យស្តីពីតុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ជប៉ុន និងតណ្ណនៃស៊ី អត្រាអតិផរណារបស់ចិន និងសេចក្តីសម្រេចពីអត្រាការប្រាក់របស់កូរ៉េខាងត្បូង។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្ដាហ៍ក្រោយៈ

<u>ថ្ងៃច័ន្ទ ទី១៥ ខែតុលា</u>

- ផលិតផលឧស្សាហកម្មរបស់ជប៉ុន ខែសីហា
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី ខែកញ្ញា
- អត្រាអ្នកអត់ការងារធ្វើនៅម៉ាឡេស៊ី ខែសីហា
- ការទូទាត់សន្និធិពាណិជ្ជកម្មរបស់អាមេរិច ខែសីហា
- ទិន្នន័យលក់រាយរបស់អាមេរិច ខែកញ្ញា

<u>ថ្ងៃអង្គារ ទី១៦ ខែតុលា</u>

- តម្លៃនាំចេញ នាំចូលរបស់កូរ៉េខាងត្បូង ខែកញ្ញា
- អត្រាអតិផរណារបស់ចិន ខែកញ្ញា
- ផលិតផលឧស្សាហកម្មរបស់អាមេរិច ខែកញ្ញា

<u>ថ្ងៃពុធ ទី១៧ ខែតុលា</u>

- ការវិនិយោគមូលបត្របំណុលបរទេសរបស់អាមេរិច ខែសីហា
- ទិន្នន័យលក់ឡានរបស់ឥណ្ឌូនេស៊ីប្រចាំឆ្នាំ ខែកញ្ញា
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់សិង្ហបុរី ខែកញ្ញា

<u>ថ្ងៃព្រហស្បតិ៍ ទី១៨ ខែតុលា</u>

- របាយការណ៍ គណៈកម្មាធិការទីផ្សារបើកទូលាយសហព័ន្ធ (Federal Open Market Committee, FOMC) របស់អាមេរិច
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ជប៉ុន ខែកញ្ញា
- ការវិនិយោគមូលបត្របំណុលបរទេសរបស់ជប៉ុន សំរាប់ថ្ងៃទី១៣ ខែតុលា
- ការសម្រេចទៅលើអត្រាការប្រាក់របស់កូរ៉េខាងត្បូង
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ប្រ៊ុយណេ ខែមិថុនា និងខែកក្កដា
- កំណើនផ.ស.ស របស់ប្រ៊ុយណេ សំរាប់ត្រីមាសទី២ ឆ្នាំ ២០១៨
- អំណះអំណាងស្ដីពីភាពអត់ការងារធ្វើនៅអាមេរិច ថ្ងៃទី ៦ ខែតុលា

<u>ថ្ងៃពុធ ទី១៩ ខែតុលា</u>

- អតិផរណារបស់ជប៉ុន ខែកញ្ញា
- អត្រាកំណើនផ.ស.សរបស់ចិន សំរាប់ត្រីមាសទី៣ ឆ្នាំ ២០១៨
- ផលិតផលឧស្សាហកម្មរបស់ចិន ខែកញ្ញា
- កំណើនឥណទានរបស់ឥណ្ឌូនេស៊ី ខែកញ្ញា
- ទិន្នន័យលក់ផ្ទះរបស់អាមេរិច ខែកញ្ញា